# មាតិកា Contents

ជីវប្រវត្តិសង្ខេបអង្គការ( ស្ការ៉ូ) ........ 3
CSARO Profile ........ 3

សាររបស់លោកនាយក ........ 4
Director's Message ........ 4

កម្មវិធីអភិវឌ្ឍន៏សហគមន៏ ........ 6
Community Development Programme ........ 6

កម្មវិធីអភិវឌ្ឍន៏អ្នករើសសំរាម ........ 10
Waste Picker Development Programme ........ 10

កម្មវិធីគ្រប់គ្រងសំណល់រឹង-សំរាម ........ 12
Solid Waste Management Programme ........ 12

កម្មវិធីអប់រំផ្សព្វផ្សាយចល័ត ........ 14
Mobile Outreach Education Programme ........ 14

កម្មវិធីណ្ឌលធនធានសហគមន៏ ........ 18
Community Resource Centre ........ 18

កម្មវិធីអភិវឌ្ឍន៏ស្ថាប័ន ........ 18
Institutional Development Programme ........ 18

# ជីវប្រវត្តិសង្ខេបអង្គការ (ស្ការ៉ូ)

អង្គការកែច្នៃ និង អនាម័យសហគមន៏ ហៅកាត់ថា (ស្ការ៉ូ) គឺជាអង្គការមិនមែនរដ្ឋាភិបាល NGO កម្ពុជាមួយ បានបង្កើតឡើងនៅក្នុង ខែកុម្ភះ ឆ្នាំ1997 ដោយក្រុមមួយនៃអ្នកធ្វើការផ្នែកអភិវឌ្ឍន៏ ដែលមានការតាំងចិត្តក្នុងការធ្វើអោយបរិស្ថានស្អាត និង ស្ថានភាពរស់នៅរបស់សហគមន៏អ្នកក្រីក្រក្នុងទីក្រុង ប្រទេសកម្ពុជាអោយមានភាពប្រសើរឡើង។ អង្គការ (ស្ការ៉ូ) ជាអ្នកនាំមុខគេក្នុងការប្រើប្រាស់នូវរបៀបធ្វើការចូលរួមមួយ ដើម្បីធ្វើអោយប្រសើរដល់ស្ថានភាពនានា នៅក្នុងតំបន់ដែលគេមិនបានយកចិត្តទុកដាក់ និង តំបន់ដែលមិនមានការបំរើសេវាទីនោះហើយជាកន្លែងដែលអ្នកក្រីក្រទីក្រុងរស់នៅ។ អង្គការ (ស្ការ៉ូ) ផ្តោតការងារពិសេសធ្វើអោយមានភាពប្រសើរឡើងដល់ស្ថានភាពរស់នៅ និង ការងាររបស់មនុស្សពេញវ័យ និង កុមាររើសសំរាមចំនួនរាប់ពាន់នាក់កំពុងរកប្រាក់ចំណូលចិញ្ចឹមជីវិតពីការដើររើសសំរាម (អេតចាយ) នៅតាមដងផ្លូវឬនៅមុខផ្ទះប្រជាពលរដ្ឋក្នុងទីក្រុងភ្នំពេញ។

**ទស្សនះវិស័យៈ-** សហគមន៏នានានៅក្នុងទីក្រុង ជាកន្លែងដែលប្រជាពលរដ្ឋ និង អ្នករើសសំរាម(អេតចាយ) ធ្វើការងារសហការជាមួយគ្នា ប្រែក្លាយតំបន់សហគមន៏កខ្វក់ទៅជាកន្លែង ស្អាត សុវត្ថិភាព សំរាប់ការរស់នៅប្រកបដោយសុខភាពល្អ និង អ្នករើសសំរាម (អេតចាយ) ទាំងអស់ ចេះធ្វើការរួមគ្នា ដើម្បីកែលំអរ ស្ថានភាព សេដ្ឋកិច្ច និង សង្គមរបស់ក្រុមពួកគេប្រសើរឡើង។

**បេសកកម្មៈ-** លើកកំពស់សមត្ថភាពប្រជាពលរដ្ឋអ្នកក្រីក្រក្នុងទីក្រុង ដើម្បីធ្វើអោយបរិស្ថានសង្គម និង ស្ថានភាពសេដ្ឋកិច្ចរបស់ពួកគេមានភាពប្រសើរឡើង។

អង្គការ (ស្ការ៉ូ) មាន 6 កម្មវិធីក្នុងផែនការយុទ្ធសាស្ត្រ 3 ឆ្នាំ (ពីខែមេសា ឆ្នាំ2004 ដល់ ខែមិនា ឆ្នាំ2007) របស់ខ្លួនពេលបច្ចុប្បន្ននេះ។ គោលបំណង សកម្មភាព និង លិត្តផលនៃកម្មវិធីទាំងនេះ បង្ហាញជូនដូចខាងក្រោមនេះ។

# CSARO Profile

Community Sanitation and Recycling Organisation (CSARO) is a Cambodian non-governmental organisation (NGO). It was established in February 1997 by a group of development workers committed to improving the environment and living conditions of the urban poor in Cambodia. CSARO is a leader in the use of participatory models to improve conditions in the areas where the urban poor live, most of which lie neglected and unconsidered. A special focus of CSARO's work is improving the living and working conditions of the thousands of adult and child waste pickers who make their living by sorting through rubbish on the street or in front of people's houses.

**Vision-** Urban communities where residents and waste pickers work together to transform low-income areas into clean, safe and healthy places to live; and where waste pickers work together to improve their social and economic conditions.

**Mission-** To encourage and motivate urban poor people to improve their capacity, their environment, and their social and economic conditions.

CSARO has six program areas in it's current three year strategic plan (2004-2007). The goals, activities and impact of these programs are highlighted on the following pages.

# សាររបស់លោកនាយក

នៅឆ្នាំ2006មានជំហានសំខាន់ៗខ្លះ ដែលបានបោះទៅមុខជាមួយនិងបញ្ហាប្រឈមមុខមួយចំនួនសំរាប់អង្គការ(ស្តារ៉ូ) ។ គឺជាឆ្នាំនៃផែនការយុទ្ធសាស្ត្រចុងក្រោយ និងការផ្តោតជាសំខាន់ទៀត គឺការត្រួតពិនិត្យមើលឡើងវិញ និងការរៀបចំផែនការយុទ្ធសាស្ត្រសំរាប់រយៈពេល 3 ឆ្នាំបន្ទាប់ ។ ជាការល្អដែលត្រូវឆ្លុះបញ្ចាំងមើលទៅលើភាពខុសប្លែកគ្នា ដែលអង្គការ(ស្តារ៉ូ) កំពុងតែធ្វើលើចំណុចពីរមានផល ប្រយោជន៏សំរាប់ការរស់នៅរបស់មនុស្សម្នាក់ៗ និងបរិស្ថានសំរាប់ប្រជាពលរដ្ឋកំពុងរស់នៅក្នុងសហគមន៏ទាំងអស់ ។

នៅឆ្នាំ 2006 នេះមានការរីកចំរើនការងារយ៉ាងធំធេងនៅក្នុងសហគមន៏ (សាមគ្គី) និងសហគមន៏ (សែន សុខ) ។ សហគមន៏ថ្មីទាំងពីរនេះមានប្រជាពលរដ្ឋអ្នកក្រីក្រច្រើនត្រូវបានផ្លាស់ចេញពីទីក្រុងភ្នំពេញ ហើយពួកគេមិនមានសម្ភារៈប្រើប្រាស់គ្រប់គ្រាន់ និងសេវាកម្មអនាម័យមានតិចតួច ។ អង្គការ(ស្តារ៉ូ) បានធ្វើការពង្រីងទៅដល់សហគមន៏ទាំងពីរនេះ ដោយការចង់ក្រុងគណៈកម្មការអភិវឌ្ឍន៏សហគមន៏ឡើង ជាតំណាងអោយប្រជាពលរដ្ឋ 6.700 នាក់ ។ ប្រជាពលរដ្ឋសហគមន៏បានទទួលការឧបត្ថមនូវសម្ភារៈឧបករណ៏ និងជំនាញផ្សេងៗ ដើម្បីលើកកំពស់ស្ថានភាពអនាម័យបរិស្ថានសំរាប់ការរស់នៅរបស់ពួកគេអោយប្រសើរឡើង ដូចជារៀបចំធ្វើសកម្មភាពអនាម័យបរិស្ថាន ការប្រមូលសំណល់-សំរាម និងការកែច្នៃសំរាមប្រើប្រាស់ឡើងវិញ ។

នៅចុងឆ្នាំ 2006 នេះមានការខកចិត្តយ៉ាងខ្លាំង ដែលតំរូវការអោយបិទមណ្ឌលអភិវឌ្ឍន៏អ្នករើសអេតចាយ (WPDC) និង មណ្ឌលអភិវឌ្ឍន៏កែច្នៃសំរាម (WRDC) នៅក្នុងទីក្រុងភ្នំពេញ ។ ពីព្រោះមណ្ឌលទាំងពីរនេះកំពុងមានសកម្មភាពអភិវឌ្ឍន៏ដំណើរការល្អនៅលើដីកម្មសិទ្ធិរដ្ឋាភិបាល ។ ដោយមានគ្រោះអាក្រក់ អង្គការ(ស្តារ៉ូ) អសមត្ថភាពមិនអាចបញ្ចុះបញ្ចូលរដ្ឋាភិបាលដើម្បីបន្តកិច្ចសន្យាកម្ចីដី ដែលមានស្រាប់នេះតទៅទៀត ។ ដោយមានហេតុការណ៏ទាំងនេះបានកើតឡើង វាតំរូវអោយអង្គការ(ស្តារ៉ូ) មានទីតាំងអចិន្ត្រៃយ៏មួយជាបន្ទាន់សំរាប់សកម្មភាពការងារអភិវឌ្ឍន៏ ។ នៅក្នុងខែតុលា បានតំរូវអោយ អង្គការ (ស្តារ៉ូ) ទិញដីមួយកន្លែង នៅក្បែរសហគមន៏ (សែន សុខ) ។ ទីតាំងដីមួយកន្លែងនោះអាចបង្កើតមណ្ឌលអភិវឌ្ឍន៏អ្នករើស(អេតចាយ) និង កែច្នៃសំរាមឡើងវិញ ហើយអាចបន្តសកម្មភាពជាច្រើនទៀត ។ ទីតាំងដីថ្មីនោះបានចាក់ដីបំពេញរួចស្រាច និង ត្រៀមរៀបចំសាងសង់មណ្ឌលដំណាក់ការទី1 នៅពេលឆាប់ៗខាងមុខនេះ ។ មណ្ឌលថ្មីនេះ នឹងផ្តល់ជាការិយាល័យដាក់ឧបករណ៏សម្ភារៈ និងកន្លែងបណ្តុះបណ្តាលរបស់អង្គការ(ស្តារ៉ូ) សំរាប់រយៈពេលវែងឆ្ងាយទៅមុខ ។

ករណីសិក្សាខ្លះបានបង្ហាញឡើងនៅឆ្នាំនេះពីលក្ខណៈឥទ្ធិពលរបស់អង្គការ(ស្តារ៉ូ) ជួយទៅដល់ជីវិតរស់នៅរបស់ស្ត្រីអ្នករើសសំរាមដែលបានចូលរួមក្នុងគំរោងសកម្មភាព ។ ការសិក្សានេះបានបង្ហាញពីរបៀបចូលរួមសកម្មភាពរបស់អង្គការ(ស្តារ៉ូ) រយៈពេលវែងទៅក្នុងសហគមន៏ជាមួយប្រជាពលរដ្ឋ និង បុគ្គលម្នាក់ៗ កំពុងតែបង្កើតអោយមានការផ្លាស់ប្តូរសមត្ថភាព និងការចិញ្ចឹមជីវិតរបស់ពួគគាត់មានភាពប្រសើរយូរអង្វែង ។ នៅពេលដែលអង្គការ(ស្តារ៉ូ) រៀបចំផែនការសំរាប់ពេលអនាគត យើងក្រឡេកឃើញពីបញ្ហាប្រឈមនៃការពង្រីងចំនួនសហគមន៏ដែលកំពុងកើនឡើង និងកសាងសមត្ថភាពអោយមានការផ្លាស់ប្តូរជារៀងដរាបនៅក្នុងចំណោមសហគមន៏អ្នកក្រីក្រក្នុងទីក្រុង ។

# Director's Message



2006 saw some important steps forward and some significant challenges for CSARO. This year represented the last full year of the current strategic plan and, as such, an important focus was on reviewing and planning for the coming years. It has been useful at this time to reflect on the differences that CSARO is making, both to the lives of individuals and to the environments in which they are living.

During 2006, the work in Samaki and Sen Sok communities grew considerably. These communities are new and the populations consist of urban slum dwellers who moved from Phnom Penh. The sites have very limited facilities and services. CSARO strengthened the community by setting up development committees to benefit more than 6,700 people. These communities are equipped with the tools and skills to improve their situation, particularly through the establishment of waste collection and recycling activities.

A major disappointment in 2006 was the need to close the Waste Picker Development Centre (WPDC) and the Waste Recycling Development Centre (WRDC) in Phnom Penh. Both of these centres were on the land borrowed from the government and, unfortunately, CSARO was unable to renew the existing lease agreement. These events underlined the urgent need for CSARO to have a more permanent base for its activities. In October, CSARO was pleased to be able to secure a place for its activities by purchasing a land near Sen Sok community. This will provide a new multipurpose centre for the site's activities. The site has already been filled and prepared and Phase 1 of the construction will begin soon. In the longer term, the site will also provide training space, offices and demonstration facilities for CSARO.

Some case studies were carried out this year to show how CSARO has impacted on the lives of women involved in its projects. The studies show how the long-term involvement of CSARO in communities and individuals is creating lasting change in people's capacity and livelihoods. As CSARO plans for the future, we look forward to the challenge of strengthening an increasing number of communities and building lasting change among the urban poor.



*Heng Yon Kora, Program Director*
*Community Sanitation and Recycling Organization*

# កម្មវិធីអភិវឌ្ឍន៍សហគមន៍

គោលបំណងស្តារ៉ូ ៖ ជួយដល់ប្រជាពលរដ្ឋក្នុងសហគមន៍ដើម្បីកែលំអរហេដ្ឋារចនាសម្ព័ន្ធ ការគ្រប់គ្រងសំណល់រឹង និងយល់ដឹងអំពីអនាម័យ ។ លើកកំពស់សមត្ថភាពអភិវឌ្ឍន៍សហគមន៍ដោយខ្លួនឯងសំរាប់អនាគតយូរអង្វែង ។



សកម្មភាពគណៈកម្មាធិការអភិវឌ្ឍន៍សហគមន៍ប្រជុំប្រចាំខែ
Monthly Community Development Committe Meeting

នៅក្នុងទីក្រុងភ្នំពេញមានតំបន់ជាច្រើនខ្វះខាតនូវហេដ្ឋារចនាសម្ព័ន្ធក្នុងសហគមន៍ ដូចជា ប្រព័ន្ធប្រឡាយ លូបង្ហូរទឹកស្អុយ ប្រព័ន្ធទឹកស្អាត ប្រព័ន្ធគ្រប់គ្រងសំណល់-សំរាម និងការចាក់សាបផ្លូវថ្នល់ ។ ហេតុដូចនេះស្ថានភាពអនាម័យបរិស្ថាន និងការគ្រប់គ្រងសំណល់-សំរាម នៅមិនទាន់ប្រសើរនៅឡើយ ដែលវាបង្កអោយប៉ះពាល់ដល់សុខភាពយ៉ាងខ្លាំង ។ អង្គការ(ស្តារ៉ូ) បានផ្តល់នូវការគាំទ្រដល់សហគមន៍នៅក្នុងការបង្កើតយន្តការដើម្បីឆ្លើយតបនូវតំរូវការទាំងនេះ ។

## គណៈកម្មាធិការអភិវឌ្ឍន៍សហគមន៍

គណៈកម្មាធិការអភិវឌ្ឍន៍សហគមន៍ (CDC's) បង្កើតឡើងដោយមានតំណាងមកពីសហគមន៍ជាមួយការគាំទ្រពីបុគ្គលិកអង្គការ(ស្តារ៉ូ) ។ គណៈកម្មាធិការអភិវឌ្ឍន៍សហគមន៍ បានរៀបចំកិច្ចប្រជុំជាទៀងទាត់ជាមួយនឹងសមាជិកដើម្បីលើកឡើងពីតំរូវការក្នុងសហគមន៍ និងសំរបសំរួលការរៀបចំផែនការដើម្បីប្រមូលធនធាន និងអនុវត្តគំរោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចៗ ។

នៅឆ្នាំ2006 បុគ្គលិកអង្គការ(ស្តារ៉ូ) បានជួយធ្វើការសំរបសំរួលដល់គណៈកម្មាធិការអភិវឌ្ឍន៍សហគមន៍ថ្មី ចំនួន 11 ក្នុងចំណោមគណៈកម្មាធិការមួយចំនួនដែលបានចងក្រងរួចចាប់តាំងពីកម្មវិធីផ្តើមមានចំនួន 54 សហគមន៍ ។ សំរាប់គណៈកម្មាធិការអភិវឌ្ឍន៍សហគមន៍ថ្មីទាំងនេះ មានប្រជាពលរដ្ឋទាំងអស់សរុប ចំនួន 1.325 គ្រួសារ ហើយមានមនុស្សសរុបច្រើនជាង 6.7700 នាក់ ។

នៅឆ្នាំនេះរៀបចំកិច្ចប្រជុំប្រចាំត្រីមាសចំនួន 5 ដង មានគណៈកម្មាធិការអភិវឌ្ឍន៍សហគមន៍ចូលរួមចំនួន 108 នាក់ ។ កិច្ចប្រជុំទាំងនេះបានផ្តល់ឱកាសដល់សមាជិកគណៈកម្មាធិការ និង បុគ្គលិកអង្គការ(ស្តារ៉ូ) ពិភាក្សាផ្លាស់ប្តូរទស្សនះ និងចែករំលែកពត៌មានគ្នាទៅវិញទៅមក ។ ប្រធានបទរួមមាន៖

- ផ្តល់ការគាំទ្រដល់ការអភិវឌ្ឍន៍ប្រឡាយលូទឹកស្អុយ និងចាក់សាប
- ពង្រីកការទំនាក់ទំនងជាមួយនឹងអាជ្ញាធរមូលដ្ឋាន
- ត្រួតពិនិត្យមើលដំណើរការវិវត្តលើការងារហេដ្ឋារចនាសម្ព័ន្ធ
- រៀបចំគំរោងផែនការ និងជ្រើសរើសគណៈកម្មាធិការគ្រប់គ្រងសំណល់រឹង-សំរាមសហគមន៍
- ធ្វើការទំនាក់ទំនងជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាលនានា

## សិក្ខាសាលាវគ្គបណ្តុះបណ្តាល

ចំណុចសំខាន់ការងារសហគមន៍អង្គការ(ស្តារ៉ូ) គឺផ្តល់ការបណ្តុះបណ្តាលស្ថាបនាសមត្ថភាព និងជំនាញ ដល់គណៈកម្មាធិការ អ្នកធ្វើការងារអភិវឌ្ឍន៍សហគមន៍ដើម្បីអោយពួកគាត់ចេះទទួលខុសត្រូវបន្តការលើកកំពស់អនាម័យបរិស្ថានសហគមន៍របស់ពួកគាត់ ។ អង្គការ(ស្តារ៉ូ)បានរៀបចំវគ្គបណ្តុះបណ្តាលជំនាញចំនួន 3 លើកសំរាប់សមាជិកគណៈកម្មាធិការអភិវឌ្ឍន៍សហគមន៍ដោយមានប្រធានបទស្តីពីជំនាញធ្វើការជាអ្នកសំរបសំរួលសហគមន៍ចំនួន 3 ថ្ងៃ ជំនាញ

# Community Development Programme

**CSARO goal:** Assist residents to improve their community infrastructure, solid waste management and hygiene knowledge. Improve community capacity to develop for a sustainable future.



Activity of community training skill
សកម្មភាពបណ្តុះបណ្តាលជំនាញដល់អ្នកសហគមន៍



Communities groups capacity building and certificate
អ្នកសហគមន៍បញ្ចប់សិក្ខាសាលា

Many areas of Phnom Penh lack basic community infrastructure, such as sewage and drainage systems, clean water systems, waste management facilities, and paved roads. As a result, hygiene and sanitation conditions are poor, in many cases leading to health problems. CSARO supports communities in establishing mechanisms which can respond to these needs.

### Community Development Committees

Community Development Committees (CDCs) are made up of representatives from the community, with support from CSARO staff. The CDCs conduct regular meetings with community members in order to identify community needs, facilitate planning, mobilise resources, and implement small-scale infrastructure projects.

In 2006, CSARO staff facilitated the formation of 11 new CDCs, bringing the total number of CDCs formed since the programme began to 54. These new CDCs represent 1,325 households in total: more than 6,700 people.

In the past year, five (5) quarterly meetings were conducted, with 108 CDC participants. The meetings provided an opportunity for CDC members and CSARO staff to exchange ideas and share feedback. Discussion topics included:

Finding support to develop drainage and paving
Developing relationships with local authorities
Reviewing the progress of infrastructure activities
Planning and selecting waste management committees
Developing network with other NGOs

### Training workshops

A vital aspect of CSARO's community work involves training. This builds the skills and capacity of CDCs and their communities so that they can take responsibility for continuing improvements to their environment. CSARO held three training workshops for CDC members, covering community facilitation skills (3 days), communication skill (2 days) and community leadership (2 days). There were 62 participants in total.

### Community exchange visits

Four community exchange visits were conducted in 2006.

# កម្មវិធីអភិវឌ្ឍន៍សហគមន៍



សកម្មភាពធ្វើប្រព័ន្ធប្រឡាយលូបង្ហូរទឹកស្អុយសហគមន៍
Urban Commonity Sewege drainage activity

ធ្វើការជាអ្នកទំនាក់ទំនងល្អចំនួន 2 ថ្ងៃ និងជំនាញជាអ្នកដឹកនាំក្នុងសហគមន៍ចំនួន 2 ថ្ងៃ មានសិក្ខាកាមបានចូលរួមចំនួន 62 នាក់។

## ទស្សនកិច្ចសិក្សាតាមសហគមន៍

ឆ្នាំ2006 នេះបានរៀបចំទស្សនកិច្ចសិក្សាតាមសហគមន៍ចំនួន 4 លើក។ គោលបំណងទស្សនកិច្ច គឺធ្វើអោយសមាជិកគណៈកម្មាធិការអភិវឌ្ឍន៍សហគមន៍ថ្មីបានយល់ដឹងពីការផ្លាស់ប្តូររៀបធ្វើការងាររួមគ្នាយ៉ាងជិតស្និទ្ធិក្នុងការអភិវឌ្ឍន៍សហគមន៍ និងសមិទ្ធិផលផ្លែផ្កានៃកិច្ចសហការជាមួយនឹងអាជ្ញាធរមូលដ្ឋាន ដើម្បីឆ្លើយតបបានប្រសើរចំពោះតំរូវការហេដ្ឋារចនាសម្ព័ន្ធរបស់សហគមន៍អ្នកក្រីក្ររស់នៅក្នុងទីក្រុង។ សមាជិកគណៈកម្មាធិការអភិវឌ្ឍន៍សហគមន៍សរុប 75 នាក់ បានចូលរួមកម្មវិធីទស្សនកិច្ចសិក្សាតាមសហគមន៍។ នេះជាលើកទីមួយហើយដែលពួកគាត់មានឱកាសបានរៀនសូត្រពីគណៈកម្មាធិការអភិវឌ្ឍន៍សហគមន៍ដ៏ទៃដែលពួកគាត់បានឃើញសហគមន៍ទាំងនោះមានការយល់ដឹងល្អ ចេះធ្វើការរួមគ្នាសំរាប់សហគមន៍ គេបានអភិវឌ្ឍន៍ល្អ។ សកម្មភាពទស្សនកិច្ចសិក្សាតាមសហគមន៍ផ្តល់ឱកាសច្រើនសំរាប់អ្នកសហគមន៍ ពួកគាត់បានផ្លាស់ប្តូរបទពិសោធន៍ពីគ្នាតាមវិធីបែបចូលរួមធ្វើការប្រសើរឡើង ហើយពួកគាត់អាចទទួលបាននូវមេរៀនដ៏មានតំលៃត្រឡប់មកវិញអំពីវិធីដើម្បីលើកកំពស់តំបន់សហគមន៍របស់ខ្លួន ក៏ដូចជាការកសាងទំនាក់ទំនងជាមួយនឹងអ្នកដទៃតាមរយៈការធ្វើទស្សនកិច្ចនេះ។

## ហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចៗ

ឆ្នាំ2006នេះ អង្គការ(ស្តារ៉ូ) ក៏បន្តជួយដល់សហគមន៍ជាច្រើនកន្លែង ដើម្បីទទួលបានគំរោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចៗ។

## ប្រព័ន្ធលូបង្ហូរទឹកស្អុយ

អង្គការ(ស្តារ៉ូ) បានជួយឧបត្ថម្ភដល់សហគមន៍ចំនួន 3 កន្លែង មានចំនួន 77 គ្រួសារ បានធ្វើការដាក់លូបង្ហូរទឹកស្អុយប្រវែង 245 ម៉ែត្រ នឹងអណ្តូងលូចំនួន 20 ធ្វើរួច។ អង្គការ(ស្តារ៉ូ) ចេញការចំណាយ 45% ហើយសហគមន៍ចូលរួមចេញការចំណាយ 55% គិតរួមទាំងថ្លៃពលកម្មរបស់ពួកគាត់ផង។

## ការចាក់ដីបំពេញនិងពង្រាប

អង្គការ(ស្តារ៉ូ) និងសាលារៀនរបស់សហគមន៍បានរៀបចំធ្វើសកម្មភាពចាក់ដីបំពេញក្នុងសាលារៀនចំនួន 2 កន្លែង ដើម្បីការពារទឹកលិចដែលមិនមានអនាម័យនៅរដូវវស្សា ហើយផ្តល់ជាគ្រឹះសំរាប់ការចាក់សាបនៅពេលអនាគតផង។ ដីដែលបានចាក់មានចំនួន $96m^3$ នៅក្នុងបរិវេណសាលាបឋមសិក្សាព្រះអង្គអេង ដែលមានចំនួនសិស្ស 825 នាក់។ អង្គការ(ស្តារ៉ូ) ចេញការចំណាយចំនួន 41.7%។ ចំនួន $240m^3$ ទៀតនៅក្នុងបរិវេណសាលាបឋមសិក្សាទួលស្លែងមានសិស្សានុសិស្ស និងគ្រូបង្រៀនទាំងអស់ចំនួន 825 នាក់ ទទួលបានផលប្រយោជន៍នេះ។ អង្គការ(ស្តារ៉ូ) ចេញការចំណាយចំនួន 16.7%។ ចំណែកសហគមន៍(ដើមខ្ទិត) វិញបានចាក់ដីបំពេញក្នុងសហគមន៍របស់ពួកគាត់ចំនួន $60.5m^3$ មានចំនួន 26 គ្រួសារ បានទទួលផលប្រយោជន៍នេះ។ អង្គការ(ស្តារ៉ូ) ចេញការចំណាយចំនួន 30.2%។ សកម្មភាពចាក់ដីបំពេញនៅចុងក្រោយចំនួន $1.040m^3$ ត្រូវបានចាក់បំពេញលើដីថ្មីសំរាប់គោលបំណងធ្វើមណ្ឌលបង្រៀនជំនាញដល់អ្នកសហគមន៍ និងអ្នករើសសំរាម(អេតចាយ)។

# Community Development Program

The purpose of these visits is to let new CDCs learn lessons from communities which work closely together and which have already achieved fruitful collaboration with local authorities allowing them to respond better to their own infrastructure needs. A total of 75 CDC members participated in the community exchange visits. For many, this was the first time they had visited another community to learn in this way, and they were able to take back valuable lessons on how to improve their own sites. It was also a good opportunity for communities to build relationships with each other.

### Small-scale infrastructure

In 2006, CSARO continued to assist communities in completing small-scale infrastructure projects.

### Sewers and surface drains

CSARO supported three communities (77 households) to lay 245m of sewer pipes, with 20 boxes for access and clearage. CSARO provided 45% of the cost and the communities 55% (including labour).

### Filling and levelling

CSARO worked with schools and communities to plan and carry out landfill. This prevents flooding during the wet season and provides a solid foundation for any future building/paving work. 96$m^3$ of soil was put down at Ang Eng School (825 students), with CSARO providing 41.7% of the cost. 240$m^3$ was filled at Toul Sleng Community School (600 students), with CSARO providing 16.7% of the cost. 60.5$m^3$ was filled in Deum Kvit Community (26 households), with CSARO providing 30.2% of the cost. Finally, the site purchased for the new multipurpose centre was filled and levelled with 1,040$m^3$ of soil.



Community organization activity
សកម្មភាពចងក្រងសហគមន៍



Filling community alleyway activity
សកម្មភាពចាក់ដីធ្វើផ្លូវលំតូចសហគមន៍



Exchange visit activity
សកម្មភាពទស្សនកិច្ចសិក្សាសហគមន៍

# កម្មវិធីអភិវឌ្ឍន៍អ្នករើសសំរាម

**គោលបំណង(ស្ការ៉ូ): ជួយអ្នករើសសំរាមអោយមានស្ថានភាពសេដ្ឋកិច្ច និង សង្គម-របស់ពួកគាត់បានប្រសើរឡើងតាមរយៈការអភិវឌ្ឍន៍ជំនាញ និងសកម្មភាពជួយខ្លួនឯង។**

## មណ្ឌលអភិវឌ្ឍន៍អ្នករើសសំរាម

ឆ្នាំ2006នេះ មណ្ឌលអភិវឌ្ឍន៍អ្នករើសសំរាម(WPDC) បានធ្វើការលើកកំពស់គុណភាពជីវិតអ្នករើសសំរាម។ មណ្ឌលបានផ្តល់ការបណ្តុះបណ្តាលលើការប្រមូលសំរាមប្រកបដោយសុវត្ថិភាព ការបែងចែកសំរាម និងការកែច្នៃផលិតផលដែលបានមកពីសំរាម។ មណ្ឌលបានផ្តល់ជា កន្លែងសំរាប់ជួបជុំអ្នករើសសំរាម កន្លែងសំរាប់សុវត្ថិភាពដល់កូនចៅរបស់ពួកគាត់បានរត់លេង និងរៀនសូត្រ ហើយមនុស្សចាស់អាចជួបជុំគ្នា ធ្វើការទំនាក់ទំនងជាមួយសង្គមបានល្អ និងពង្រីកបណ្តាញកិច្ចការសង្គមកិច្ច។ មានការកើនឡើងយ៉ាងច្រើននូវចំនួនអ្នករើសសំរាម(អេតចាយ) ចូលមកប្រើប្រាស់មណ្ឌលនៅក្នុងឆ្នាំ2006នេះជាមធ្យមពី 95នាក់ ទៅ 120នាក់ ជារៀងរាល់ថ្ងៃ។

មណ្ឌលនៅតែបន្តផ្តល់កន្លែងងាយស្រួលសំរាប់ ផ្នែកអនាម័យ ផ្នែកសង្គ្រោះបឋម និង ការថែទាំបញ្ហាសុខភាពទូទៅ ព្រមទាំងបញ្ជូនអ្នកមានជំងឺធ្ងន់ធ្ងរទៅកាន់គ្លីនិក ឬ មណ្ឌលសុខភាព។ មានផ្តល់ព្រឹក្សាយោបល់ពីបញ្ហាសុខភាពស្ត្រី និងកុមារីរើសសំរាម (អេតចាយ) ដូចជាបញ្ហាសុខភាពបន្តពូជ ការពន្យាកំណើត ការជួញដូរកុមារ ការរំលោភបំពាបំពានផ្លូវភេទ ការប្រើគ្រឿងញៀន សុខភាពផ្លូវចិត្ត និងអំពើហិង្សាក្នុងគ្រួសារ។ ស្ត្រី និងកុមារីបានទទួលសេវាកម្មទាំងនេះតាមរយៈបុគ្គលិកកម្មវិធីអប់រំផ្សព្វផ្សាយចល័តធ្វើការសំរបសំរួលនៅក្នុងមណ្ឌល។

ប៉ុន្តែមណ្ឌលនេះត្រូវបានបិតនៅចុងឆ្នាំ 2006 នេះ គឺជាការខកចិត្តយ៉ាងខ្លាំង។ បុគ្គលិកអង្គការ(ស្ការ៉ូ) ធ្វើការរុះរើមណ្ឌលដោយមិនមានការរំខាន់ទៅអ្នកដទៃទេ យ៉ាងប្រយ័ត្នប្រយែងបំផុត។ អ្នករើសសំរាម(អេតចាយ)ទាំងអស់ត្រូវផ្លាស់ទៅកន្លែងដ៏តូចមួយ នៅក្នុងការិយាល័យអង្គការ(ស្ការ៉ូ)។ សកម្មភាពផ្សេងៗទៀត ដែលមានក្នុងមណ្ឌលពីមុនត្រូវបានបំបែក ហើយបង្កើនកន្លែងជួបជុំជាច្រើនបន្ថែមនៅជុំវិញទីក្រុង ដោយប្រើរថយន្តចល័ត។ សកម្មភាពសំខាន់ៗ ភាគច្រើននៅតែបន្តដូចពីមុនដដែល។

ផ្នែកសំខាន់នៃការងារនេះគឺជួយសំរួលចង់ក្រុង និងបណ្តុះបណ្តាលដល់អ្នករើសសំរាមក្រុមជួយខ្លួនឯង(SHGs) ហើយបានជួយគាំទ្រពួកគេអោយចេះធ្វើការរួមគ្នាលើកកំពស់ស្ថានភាពរស់នៅរបស់ពួកគេផ្ទាល់ខ្លួន។ នៅឆ្នាំ2006 ក្រុមជួយខ្លួនឯងថ្មីបានបន្តទទួលការបណ្តុះបណ្តាល និង ការជួយឧបត្ថមសំភារៈផងដែរ។ ក្រុមជួយខ្លួនឯងថ្មីទាំងនេះមានសមាជិកចំនួន 12នាក់ បានចាប់ផ្តើមធ្វើការនៅក្នុងសហគមន៍ (សែនសុខ) របស់ពួកគេ។

## ការបណ្តុះបណ្តាល និង ទស្សនកិច្ចសិក្សា

ឆ្នាំ 2006 បានរៀបចំការបណ្តុះបណ្តាលចំនួន 4វគ្គ ដល់អ្នករើសសំរាមក្រុមជួយខ្លួនឯង និង សហគមន៍អ្នកក្រីក្ររស់នៅក្នុងទីក្រុងដើម្បីបង្កើនសមត្ថភាពពួកគាត់ចេះធ្វើការងារលើជំនាញធ្វើជីកំប៉ុស និងររបៀបរកទីផ្សារចំនួន 5ថ្ងៃ ការគ្រប់គ្រង និង ភាពជាអ្នកដឹកនាំចំនួន 3ថ្ងៃ ការប្រមូលសំរាមបឋមតាមសហគមន៍ចំនួន 5ថ្ងៃ និងរបៀបធ្វើការចុះបញ្ជីស្នាមចំណាយចំណូលចំនួន 30ថ្ងៃ។ អ្នកសហគមន៍និងក្រុមជួយខ្លួនឯងបានចូលរួមបណ្តុះបណ្តាលទាំងអស់ខាងលើនេះចំនួន 42នាក់ ក្នុងនោះមានស្ត្រី 21នាក់។

អ្នករើសសំរាមក្រុមជួយខ្លួនឯងបានរៀបចំការប្រជុំប្រចាំត្រីមាសដើម្បីជួបជុំសមាជិករបស់ពួកគាត់។ សមាជិកមកចូលរួមចំនួន 116 នាក់ (ស្ត្រី 82 នាក់) ការប្រជុំពិភាក្សាលើប្រធានបទដូចខាងក្រោមនេះ:

- ការបង្កើនតផលិតកែច្នៃរបស់ក្រុមជួយខ្លួនឯង
- ការបង្កើនគុណភាពការផលិតកែច្នៃ
- ការបង្កើនផលិតកែច្នៃលើទីផ្សារ
- ការផ្លាស់ប្តូរមណ្ឌលអភិវឌ្ឍន៍អ្នករើសសំរាម
- បញ្ហាការប្រមូលសំរាមបឋមនៅក្នុងសហគមន៍

ការបណ្តុះបណ្តាលជំនាញកែច្នៃសំរាមបានរៀបចំឡើងនៅក្នុងមណ្ឌលអភិវឌ្ឍន៍អ្នករើសសំរាម។ ឆ្នាំ2006 បានរៀបចំបណ្តុះបណ្តាល ជំនាញកែច្នៃសំរាមចំនួន 2វគ្គ លើការបែងចែកសំរាមតាមផ្ទះ ចំនួន 35ថ្ងៃ ការកែច្នៃសំណល់ថង់ប្លាស្ទិកចំនួន 2វគ្គ ចំនួន 20ថ្ងៃ ការ កែច្នៃសំណល់ក្រដាសចំនួន 2វគ្គ ចំនួន 10ថ្ងៃ ការកែច្នៃសំណល់ ក្រណាត់ចំនួន 2វគ្គ ចំនួន 30ថ្ងៃ និង ការងារធ្វើជីកំប៉ុស។ អ្នករើសសំរាម(អេតចាយ)បានចូលរួមការបណ្តុះបណ្តាលជំនាញមានចំនួន 69 នាក់ ។ អង្គការ(ស្ការ៉ូ) នៅតែបន្តជួយសំរបសំរួលការលក់ផលិតផលកែច្នៃគ្រប់មុខហើយបញ្ជូនប្រាក់កំរៃទាំងអស់នោះអោយទៅក្រុមគោលដៅ។

អង្គការ(ស្ការ៉ូ)ផ្តល់ការបណ្តុះបណ្តាលលើសមត្ថភាពផ្សេងៗទៀតអោយទៅអ្នករើសសំរាមក្រុមជួយខ្លួនឯង។ បណ្តុះបណ្តាលគ្រូបង្គោល ចំនួន 3 ថ្ងៃ សំរាប់អ្នកចង់ធ្វើការងារជាគ្រូបង្គោល មានចំនួន 12 នាក់ ដើម្បីបង្ហាត់បង្ហាញជំនាញកែច្នៃសំរាមទៅដល់អ្នករើសសំរាមក្រុមជួយខ្លួនឯងថ្មីដទៃទៀត។

បុគ្គលិកអង្គការ(ស្ការ៉ូ)បានជួយរៀបចំទស្សនកិច្ចសិក្សា ជាមួយក្រុមជួយខ្លួនឯងអ្នករើសសំរាមចំនួន 40 នាក់ ដែកពួកគាត់កំពុងធ្វើការនៅក្នុងមណ្ឌលអភិវឌ្ឍន៍កែច្នៃសំរាមសហគមន៍ (សាមគ្គី) និងសហគមន៍ (សែន សុខ)។ ការធ្វើដំណើរទស្សនកិច្ចសិក្សានេះបានទៅទីក្រុងព្រះសីហនុដើម្បីអោយពួកគាត់មានឱកាសស្តាបនា និង យល់ដឹងល្អពីការទំនាក់ទំនងសហគមន៍ខុសៗគ្នា។

# Waste Picker Development Programme

**CSARO goal:** Assist waste pickers to better their social and economic conditions through skills development and self-help activities.

**Waste Picker Development Center**

Throughout 2006, the WPDC worked to improve quality of life for waste pickers. The WPDC provides training in safe waste collection and separation and in making products from recycled materials. It also offers a meeting place for waste pickers, providing a safe space for children to play and learn and for adults to meet, socialise and develop support networks. The WPDC was increasingly used during 2006, with the average number of visits rising from 95 to 120 people everyday.

The WPDC continued to provide sanitation facilities and to deal with first aid and general healthcare issues, referring serious health issues to clinics. A counselling and discussion group allows women and girl waste pickers to address issues of reproductive health, birth spacing, child trafficking, harassment, sexual abuse, drug abuse, mental health and domestic violence. The numbers involved in these activities are reported under the Mobile Outreach Education Programme, which took over coordination of these activities.

The closure of the WPDC at the end of 2006 was a major disappointment. CSARO staff managed the closure carefully to ensure minimal disruption. The waste picker activities moved to a smaller area near the CSARO office. By supplementing this with increased use of the CSARO mobile van and establishment of more meeting points around the city, the majority of the WPDC's work has been able to continue as before.

An important part of this work is facilitating the creation and training of self-help groups (SHGs). Members work together and support each other to improve their own situations. In 2006, existing SHGs continued to receive training (see below) and support. A new SHG with 12 members was started in Sen Sok community.

**Training and exchange visits**

In 2006, four workshops were held for waste picker SHGs, building their capacity in the areas of compost and marketing (five days), management and leadership (three days), community primary waste collection (five days) and marketing and bookkeeping (30 days). A total of 42 (21 women) waste pickers participated in these workshops.
Quarterly meetings were also arranged for self-help groups. A total of 116 waste pickers (82 women) attended these meetings, where discussion and training took place on the following subjects:



Pepar waste handicraft and recycle activity
សកម្មភាពកែច្នៃសំណល់-សំរាមក្រដាស

- Recycling as production
- Quality of recycling products
- Marketing
- Moving the WPDC
- Primary waste collection in the community

Training workshops on recycling skills were also held at the WPDC. During 2006, two courses were run on household waste recycling (35 days); two on plastic waste recycling (20 days); two on paper recycling (10 days); and 1 workshop on cloth recycling (30 days). Composting skills were also taught. A total of 69 participants benefited from the training. CSARO continued to facilitate the sale of recycled items on behalf of those who made them, passing all the profit back to the participants.

CSARO seeks to give others the capacity to deliver this training wherever possible. A three-day training of trainers workshop was held for 12 people, dealing with methods of teaching recycling skills.

With the help of CSARO staff, 40 waste pickers from the WRDC and from Samaki and Sen Sok communities went to Kompong Som for an exposure visit. The visit built relationships and facilitated a good understanding between the different communities.

# កម្មវិធីគ្រប់គ្រងកាកសំណល់រឹង

គោលបំណង(ស្ការ៉ូ)៖ ជួយដល់ប្រជាពលរដ្ឋអ្នកក្រីក្រ អំពីការគ្រប់គ្រងសំណល់រឹង-សំរាម នឹងការយល់ដឹងអនាម័យបរិស្ថានក្នុងសហគមន៍របស់ពួកគេប្រសើរឡើង។

## មណ្ឌលអភិវឌ្ឍន៍កែច្នៃសំរាម

មណ្ឌលអភិវឌ្ឍន៍កែច្នៃសំរាម (WRDC) នៅបន្តដំណើរការក្នុងឆ្នាំ 2006 ហើយមានក្រុមជួយខ្លួនឯងអ្នករើសសំរាមចំនួន 9 នាក់ ធ្វើការប្រមូលសំរាមសរីរាង្គក្នុងទីផ្សារ និងតាមផ្ទះមួយចំនួននៅក្បែរៗមណ្ឌលដើម្បីកែច្នៃធ្វើជីកំប៉ុស។ មណ្ឌលនេះជាកន្លែងធ្វើជីកំប៉ុសដើម្បីបង្កើនប្រាក់ចំណូលទូលទៅសំរាប់ក្រុមជួយខ្លួនឯង ហើយក៏ជាកន្លែងសំរាប់ធ្វើការបណ្តុះបណ្តាល និង ពិសោធន៍ពីរបៀបកែច្នៃសំរាមធ្វើជីកំប៉ុសទៅដល់សហគមន៍អ្នកក្រីក្ររស់នៅក្នុងទីក្រុងទូទៅដែលពួកគាត់ចង់ចេះជំនាញទាំងនេះ។ ការប្រមូលសំរាមសរីរាង្គកែច្នៃបាននៅក្នុងឆ្នាំនេះ ចំនួនជាង 297.000 គ.ក ស្មើរនិង 297 តោន។ ជីកំប៉ុសធ្វើបានចំនួនសរុប 14.617 គ.ក ហើយលក់បានជាប្រាក់ចំណូលបានចំនួន 1.258 ដុល្លារ សំរាប់ក្រុមរបស់ពួកគេដែលបានធ្វើការនៅក្នុងមណ្ឌលអភិវឌ្ឍន៍កែច្នៃសំរាម។ ក្រុមអ្នករើសសំរាមទាំងអស់ត្រូវបានលើកទឹកចិត្តអោយធ្វើការសន្សំប្រាក់ពីចំណូលរបស់ពួកគេ។ ចំណែការសិក្សាស្រាវជ្រាវក្នុងមណ្ឌលនៅតែបន្តការពិសោធន៍ដ៏មានប្រសិទ្ធភាពល្អបំផុតអំពីវិធីធ្វើជីកំប៉ុសពីសំរាមសរីរាង្គ និងជីកំប៉ុសដែលបានផលិតរួច។

មានការសោកស្តាយខ្លាំងណាស់ចំពោះមណ្ឌលអភិវឌ្ឍន៍កែច្នៃសំរាម ដែលមានបច្ចុប្បន្ននេះត្រូវបានបិទនៅចុងឆ្នាំ2006នេះ នៅពេលកិច្ចសន្យាលើទីតាំងនោះត្រូវបានបញ្ចប់។ សកម្មភាពការងារជាច្រើនត្រូវបានផ្លាស់ទៅកាន់ទីតាំងដីថ្មីដែលអង្គការ(ស្ការ៉ូ)បានទិញជាបន្ទាន់ តម្រូវការសាងសង់មណ្ឌល និង កន្លែងធ្វើជីកំប៉ុសជាចាំបាច់។

## ការប្រមូលសំរាមបឋមតាមសហគមន៍

ឆ្នាំ2006 អង្គការ(ស្ការ៉ូ) នៅតែបន្តការងារជាមួយសហគមន៍(សាមគ្គី)នៅក្នុងទីក្រុង ដើម្បីប្រមូល និង កែច្នៃសំរាម។ សហគមន៍នេះមានភាពប្រសើរកើនឡើងយ៉ាងខ្លាំង ផ្នែកអនាម័យបរិស្ថានក្នុងសហគមន៍ពួកគេ។ សមាជិកក្រុមជួយខ្លួនឯង 6 នាក់ បានធ្វើការប្រមូលសំរាមជារៀងរាល់ថ្ងៃ សំរាមជាង 415 តោន ដែលធ្វើការប្រមូលពីផ្ទះប្រជាពលរដ្ឋចំនួន 450 គ្រួសារ រយៈពេលមួយឆ្នាំនេះ។ សំរាមទាំងអស់នោះត្រូវបានធ្វើការបែងចែកតាមប្រភេទ ចំណែកសំរាមសរីរាង្គធ្វើជីកំប៉ុស ទន្ទឹមនោះសំរាម(អេតចាយ)ក៏បានលក់ផងដែរ។ ចំពោះសំរាមនៅសល់(មិនអាចប្រើកើត)បញ្ជូនចេញពីសហគមន៍ដោយក្រុមហ៊ុនឯកជន។ សកម្មភាពប្រមូលសំរាមតាមសហគមន៍បានផ្តល់ប្រាក់កំរៃពលកម្ម នឹងប្រាក់លក់(អេតចាយ) ចំនួន 453 ដុល្លារ នឹងលក់ជីកំប៉ុសចំនួន 1.595 គ.ក បានលុយចំនួន 123 ដុល្លារ ទៅដល់ក្រុមជួយខ្លួនឯងអ្នករើសសំរាម។

បុគ្គលិកអង្គការ(ស្ការ៉ូ) ក្រុមជួយខ្លួនឯង និងគណៈកម្មាធិការអភិវឌ្ឍន៍សហគមន៍(សាមគ្គី) បានរៀបចំប្រជុំប្រចាំត្រីមាសចំនួន 4 លើក។ អ្នកចូលរួមចំនួន 48 នាក់ បានពិភាក្សា លើការបង្កើនធ្វើជីកំប៉ុស ការជ្រើសរើសក្រុមជួយខ្លួនឯងបន្ថែម ការរៀបចំគណៈកម្មាធិការ និងការរៀបចំផែនការការងារ។ នៅសហគមន៍(សាមគ្គី) បានទទួលរទេះរុញដឹកសំរាមចំនួន 10 គ្រឿង ធុងដាក់សំរាមខ្នាតធំចំនួន 10 ធុង សំភារៈសំរាប់ជួសជុលរទេះ 2 ប្រអប់ នឹងធុងសំរាមខ្នាតតូចៗ ចំនួន 600 ធុង ត្រូវបានចែកជូនដល់ប្រជាពលរដ្ឋ ដើម្បីងាយស្រួលធ្វើការបែងចែកសំរាម និងដាក់សំរាម។

នៅខែធ្នូ ឆ្នាំ2006 អង្គការ(ស្ការ៉ូ) មានការគាំទ្រចូលរួមពីរដ្ឋាករគ្រប់គ្រងសំណល់រាជធានីភ្នំពេញ និងប្រជាពលរដ្ឋរស់នៅក្នុងសហគមន៍ (សែន សុខ) បានបើកសម្ពោធការប្រមូលសំរាមបឋមឡើង។ នេះជាការងារមួយដ៏សំខាន់របស់អង្គការ(ស្ការ៉ូ)បានពង្រីកតំបន់ សហគមន៍ ហើយជួយបង្កើនការងារដល់អ្នកសហគមន៍ ព្រមទាំងជួយលើកកំពស់អនាម័យបរិស្ថានទៅដល់សហគមន៍អ្នកក្រីក្ររស់នៅក្នុងទីក្រុង ដែលមានចំនួនច្រើនជាង 1.466 គ្រួសារ (ហើយមានប្រជាពលរដ្ឋចំនួន 8.228 នាក់)។

# Solid Waste Management Programme

**CSARO goal:** Assist residents to improve their communities in terms of solid waste management and hygiene knowledge.

### Waste Recycling Development Centre

The WRDC continued to operate throughout 2006, with up to nine people in self-help groups (SHGs) recycling organic waste from nearby markets and households. This activity generated income while the WRDC also served as a demonstration and testing centre. The total amount of organic waste collected and recycled over the year was over 297,000kg, or 297 tons. In total, 14,617kg of compost was sold, generating US$1,258 for those working at the WRDC. The groups were encouraged to save this income. Research continued at the WRDC into the most effective means of composting waste and testing the effectiveness of compost after production.

It was very disappointing to have to close the WRDC at the end of 2006 when the site lease expired. Activities will be moved to a new site purchased by CSARO as soon as the necessary buildings and composting bins can be constructed.

### Community primary waste collection

During 2006, CSARO continued to work with SHGs to collect and recycle waste in the urban communities of Samaki. There have been significant improvements in sanitation in these communities. Six SHG members carried out daily waste collection, gathering over 415 tons of waste from 450 households during the year. This waste was sorted and the organic waste was recycled; any recyclable goods were sold. The remaining (unusable) waste was passed to a private company which collects waste from the recycling centre in Samaki. The collection of waste provided additional income for the SHGs of US$453 from sales of recyclable waste and about US$123 from sales of the 1,595kg of compost.

CSARO continued to organise quarterly meetings for SHGs and CDCs in Samaki. Altogether, 48 participants joined the four meetings, discussing the development of and selection of members for SHGs; composting methods; committee organisation; and work planning. In addition, 10 pushcarts, 10 waste containers and two sets of tools were designed, tested and put into use. 600 garbage bins were distributed to improve waste collection and separation.

In December 2006, CSARO, with support from Phnom Penh Waste Management and communities, inaugurated waste collection in Sen Sok community. This important expansion of CSARO's work will create jobs and improve sanitation in this slum community of 1,496 families (around 8228 people).



Community compost shreding
ម៉ាស៊ីនកិនសំរាមសរីរាង្គធ្វើជីកំប៉ុសសហគមន៍



Community compost testing with plant
ការពិសោធន៍ដំណាម ជីកុំប៉ុសសហគមន៍

# កម្មវិធីអប់រំផ្សព្វផ្សាយចល័ត

គោលបំណង(ស្ការ៉ូ)៖ ជួយអ្នករើសសំរាមឱ្យមានស្ថានភាពសង្គម និងសេដ្ឋកិច្ចរបស់ពួកគេបានប្រសើរឡើងតាមការអភិវឌ្ឍន៍ជំនាញ និងសកម្មភាពជួយខ្លួនឯង។ លើកកំពស់សមត្ថភាពសហគមន៍ ដើម្បីអភិវឌ្ឍន៍ខ្លួនឯងសំរាប់អនាគតយូរអង្វែង។



សកម្មភាពអប់រំចល័តដល់កុមាររើសសំរាម
Mobile Teaching waste pickers chidren Activity

កម្មវិធីអប់រំផ្សព្វផ្សាយចល័តបានទៅដល់កន្លែងអ្នករើសសំរាមរស់នៅ និងកន្លែងពួកគេដើររើសសំរាមតាមផ្លូវទីសាធារណៈ។ ការបង្រៀនធ្វើទៅតាមកន្លែងអ្នករើសសំរាមមនុស្សចាស់ និង កុមារអាចជួបជុំគ្នាបាន។ ការបង្រៀននេះផ្តល់តាមរថយន្តចល័តពី 4 ទៅ 6 ដងក្នុងមួយថ្ងៃៗនៅទីតាំងផ្សេងៗគ្នា ហើយជារឿយមានអ្នករើសសំរាមបានចូលរួមច្រើនជាង 130 នាក់ មានអាយុចាប់ពី 7 ដល់ 18 ឆ្នាំ។

### ការអប់រំអ្នករើសសំរាម

ឆ្នាំ2006 ក្រុមអប់រំផ្សព្វផ្សាយចល័តបានចុះបង្រៀនតាមតំបន់គោលដៅចំនួន 18 កន្លែង ក្នុងនោះមាន 12 កន្លែងនៅពេលថ្ងៃ និង 6កន្លែងនៅពេលយប់។ នៅអំឡុងពេលមួយឆ្នាំនេះការអប់រំផ្សព្វផ្សាយចំនួន 1.035 លើក មានអ្នករើសសំរាមជាង 300 នាក់។ ការអប់រំផ្សព្វផ្សាយនេះផ្តោតលើអនាម័យផ្ទាល់ខ្លួន អនាម័យចំណីអាហារ បញ្ហាសុខភាព ការប្រើម៉ាស ការដោះស្រាយបញ្ហាជំងឺឆ្លង និងការប្រមូលសំរាមប្រកបដោយសុវត្ថិភាព។ ការជួបជុំរៀនសូត្រនេះផ្តល់តាមកំរិតថ្នាក់ខុសៗគ្នា អ្នករើសសំរាមដែលចេះអាន ចេះសរសេរ និងអ្នកមិនចេះអាន មិនចេះសរសេរ វិធីសាស្ត្របង្រៀនដូចជា ចៀង សម្តែងរឿង គំនូររូបភាព និងការពិភាក្សាជាក្រុម។ ក្រុមបុគ្គលិកបង្រៀនចល័ត ធ្វើការបង្កើតនូវសម្ភារៈឯកសារថ្មីៗជាប្រចាំផងដែរ ហើយបានរៀបចំចង់ក្រងមេរៀនថ្មីចំនួន 65 មេរៀន រូបភាពថ្មីចំនួន 99 រូបភព ឯកសារមេរៀនទាំងនេះបានធ្វើការចែកចំនួន 597 សន្លឹក។ អ្នកចូលរួមភាគច្រើនជាកុមារ ចំណុចសំខាន់នៃកម្មវិធីនេះគឺធ្វើការបង្រៀនអោយ ចេះអានអក្សរ និងលេខ។ អ្នកដែលបានចូលរួមក្នុងកម្មវិធី នេះត្រូវបានលើកទឹកចិត្តអោយចូលសាលារៀនវិញតាមដែលអាចធ្វើទៅបានដើម្បីបង្កើនចំណេះដឹងទូទៅរបស់ពួកគេ។

ផ្តល់ការបង្រៀនអំពីការសង្គ្រោះបឋមទៅកុមារ និងមនុស្សចាស់ដើម្បីចេះធ្វើការព្យាបាលរបួសរបស់ពួកគេបានដោយខ្លួនឯង។ គ្រូៗបានផ្តល់ការផ្គត់ផ្គង់គ្រឿងបរិក្ខាជាមូលដ្ឋានដូចជា ស្រោមដៃ ទឹកអ៊ីយ៉ូឌីននិងបង់បិទ។ អ្នករើសំរាមម្នាក់ៗបានទទួលការអប់រំ និងការព្យាបាលក្នុងមណ្ឌលអភិវឌ្ឍន៍អ្នករើសសំរាមផងដែរ មានមនុស្សចាស់និងកុមារអ្នករើសសំរាមបានទទួលការជួយសង្គ្រោះបឋមចំនួន733 នាក់។ មានករណីធ្ងន់ធ្ងរ 4 នាក់ ត្រូវបានបញ្ជូនទៅកាន់មន្ទីរពេទ្យ។

ចំពោះស្ត្រី និងកុមារីវិញបានផ្តល់ការជួយពិគ្រោះយោបល់អំពីបញ្ហាសុខភាពផ្លូវភេទ ការបំពារបំពានផ្លូវភេទ ការរៀបចំផែនការគ្រួសារ អំពើហិង្សាគ្រួសារ និងសុខភាពផ្លូវចិត្ត។ មានចំនួន 33 នាក់ទទួលបានការពិគ្រោះយោបល់ ហើយ 2 នាក់ បានបញ្ជូនទៅកាន់គ្លីនិកសុខភាព។

ការងារសំខាន់ៗរបស់ក្រុមបុគ្គលិកអប់រំផ្សព្វផ្សាយចល័តអង្គការ

# Mobile Outreach Programme

**CSARO goal:** Assist waste pickers to better their social and economic conditions through skills development and self-help activities. Improve communities' capacity to develop for a sustainable future.

The Mobile Outreach Programme seeks to reach waste pickers where they are, taking education activities into the communities where adult and child waste pickers work and congregate. Four to Six 6sessions are conducted each day in different locations using a mobile van. Often, more than 30 people participate, usually between 7 to 18 years old.

### Waste picker education

The mobile outreach team visited 18 sites regularly throughout most of 2006: 12 during the daytime and six at night. During the year, there were 1,035 training sessions in total, to over 300 waste pickers. These sessions covered personal and food hygiene, health issues (such as use of masks and dealing with common infections), and safe garbage collection. The training was delivered at different levels depending on literacy, using songs, role play, pictures and discussion. The team is constantly creating new materials, and produced 65 new lesson plans, 99 new session plans and 105 new pictures during the year as well as distributing 597 handouts. The majority of those who attend are children, so an important aspect of this programme is education in literacy and numeracy. Those who attend are encouraged to go to school where possible to build up their skills.

First aid treatment is taught so that children and adults can treat their own and others' injuries. The team provides basic supplies such as gloves, iodine and bandages. Individuals are treated in sessions and at the Waste Picker Development Centre. A total of 830 adults and children were helped in this way during 2006. Four more serious cases were referred to other medical service providers.

For women and girls, counselling sessions on issues such as reproductive health, sexual abuse, family planning, domestic violence and mental health are provided. 33 waste pickers attended these sessions during 2006. Two individuals were referred on to health clinics.



Children group discussion and tell story
សកម្មភាពពិភាក្សាជាក្រុម និង និទានរឿងកុមាររើសសំរាម



First Aid waste picked children activity
សកម្មភាពសង្គ្រោះបឋមកុមាររើសសំរាម

An important aspect of CSARO's work with this group is building support relationships among those who are out on the streets, particularly children, who are often in vulnerable

# កម្មវិធីអប់រំផ្សព្វផ្សាយចល័ត

(ស្តារ៉ូ) គឺធ្វើការស្ថាបនាទំនាក់ទំនង ហើយជួយអ្នករើសសំរាម (អេតចាយ)នៅតាមដងផ្លូវ ជាពិសេសកុមារ ជារឿយៗពួកគេស្ថិតនៅក្នុងស្ថានភាពងាយរងគ្រោះ។ នៅឆ្នាំ 2006 នេះ មានកុមាររើសសំរាម(អេតចាយ)ច្រើនជាង 45 នាក់ បានចូលរួមនៅក្នុងទិវាសិទ្ធិកុមារអន្តរជាតិនៅរាជធានីភ្នំពេញ។ មានបដា និង ផ្ទាំងរូបភាពធំៗផ្សព្វផ្សាយពីការលើកកំពស់បរិស្ថាន ហើយកុមារៗអ្នករើសសំរាម (អេតចាយ)ទាំងនោះមានឱកាសបានជួបជុំរៀនសូត្រពីកុមារដទៃទៀត។ នៅឆ្នាំដដែលមានកុមារចំនួន 45 នាក់ទៀត ក៏បានធ្វើដំណើរទស្សនកិច្ចសិក្សានៅរមណីដ្ឋានភ្នំតាម៉ៅ។ កម្មវិធីទស្សនកិច្ចនេះបានផ្តល់ឱកាសកុមាររើសសំរាម(អេតចាយ) បានស្វែងយល់ដឹងអំពីបរិស្ថានល្អ និង សកម្មភាពសង្គមនានាផងដែរ។



សកម្មភាពជួយសង្គ្រោះបឋមដល់មិត្តភ័ក្តិពួកគេ
First aid treatment thier freind activity



ការបង្រៀនរបៀបលាងដៃស្អាត
Session on how to clean hand

### ការអប់រំអ្នកសហគមន៍

អង្គការ(ស្តារ៉ូ) មានសកម្មភាពអប់រំផ្សព្វផ្សាយតាមបណ្តាសហគមន៍អ្នកក្រីក្ររស់នៅក្នុងទីក្រុង និង សាលារៀនមួយចំនួនផងដែរ។ នៅឆ្នាំ2006នេះ តាមបណ្តាកុមារសិស្សសាលាមានចំនួន 672 នាក់ បានចូលរួម ហើយទទួលបានមេរៀនចំនួន 37មេរៀន លើប្រធានបទអំពីអនាម័យចំណីអាហារ បញ្ហាចោលសំរាម និងការយល់ដឹងបែងចែកសំរាមក្នុងសាលារៀន។ មេរៀននីមួយៗមានវិធីសាស្ត្រដូចជាការពិភាក្សាជាក្រុម ការសម្តែងរឿង។

ការអប់រំផ្សព្វផ្សាយតាមសហគមន៍ (សាមគ្គី) និង សហគមន៍ (សែន សុខ) ដើម្បីស្ថាបនាប្រជាពលរដ្ឋអោយយល់ដឹងពីបញ្ហាបរិស្ថាន។ នៅថ្ងៃទី 5 ខែមិថុនា ឆ្នាំ2006នេះ បានធ្វើការរៀបចំបើកយុទ្ធនាការធំ 1 រយះពេល 1 ថ្ងៃ មានប្រជាពលរដ្ឋបានចូលរួមច្រើនជាង 800 នាក់ មកពីអង្គការជាតិ អន្តរជាតិ មន្ត្រីរដ្ឋាភិបាល គ្រូបង្រៀន សិស្សសាលា ហើយនិងប្រជាពលរដ្ឋអ្នកសហគមន៍តាមបណ្តាខណ្ឌនានានៅក្នុងក្រុងភ្នំពេញ។

បន្ថែមពីនេះក៏បានរៀបចំអប់រំផ្សព្វផ្សាយចំនួន 5 លើក អំពីការបែងចែកសំរាមទៅដល់ប្រជាពលរដ្ឋចំនួន 113 នាក់ នៅសហគមន៍ (សាមគ្គី)។ ឯកសារមេរៀនអំពីការបែងចែកសំរាមមានចំនួន 12 មេរៀន ត្រូវបានចែកជូនអ្នកចូលរួមចំនួន 161 នាក់។ ចំណែកអ្នកចូលរួមម្នាក់ៗបានទទួលឯកសារ និងធុងសំរាមតូចៗចំនួន 2 សំរាប់ធ្វើការបែងចែកសំរាមនឹងដាក់សំរាមតាមផ្ទះរបស់ពួកគេ។

# Mobile Outreach Program

situations. In 2006, over 45 children participated in Children's Rights Day in a Phnom Penh park. Banners and posters promoted environmental issues and children had the opportunity to meet and learn from other children. Later in the year, 45 children went on an exposure trip to Tamao Mountain. This trip included lessons on environmental issues, learning sessions and social activities.

### Community education

CSARO also conducts community-based education activities in urban slum communities and schools. During 2006, 672 children participated in 37 classroom sessions dealing with food hygiene, rubbish disposal in schools and the importance of waste separation. The sessions included discussion and role play. All participants received handouts and materials on each topic.

A particular focus was community education in Samaki and Sen Sok communities, building people's awareness on environmental issues. Two major one-day campaigns were organised during the year. On 5th of June 2006, a group of around 800 people (local NGOs, International NGOs, governmental officers, residents from seven districts in Phnom Penh, schools children and teachers) including CDC staff and waste pickers from CSARO participated in the campaign.

In addition, five one-day sessions on waste separation were delivered to 113 participants in Samaki early in the year. Later on, 12 sessions on waste separation were delivered to 161 participants. Each participant received handouts, training materials and two small waste bins to use for waste separation.



Game learning activity
សកម្មភាពល្បែងយល់ដឹង



.Waste Picker Children Campimg Activity
ភាពរីករាយរបស់កុមាររើសសំរាមនៅពេលបើកជំរុំ



Waste Picker groups game learning activity
ការរៀនសំដែងរបស់កុមាររើសសំរាម

# មណ្ឌលធនធានសហគមន៍

**គោលបំណង(ស្តារ៉ូ)៖ លើកកំពស់សមត្ថភាពសហគមន៍ ដើម្បីអភិវឌ្ឍន៍ខ្លួនឯងសំរាប់អនាគតយូរអង្វែង។**

មណ្ឌលធនធានសហគមន៍ មានបណ្ណាល័យឯកសារតូចមួយសំរាប់សហគមន៍ប្រើប្រាស់ពីរបៀបរៀបចំអភិវឌ្ឍន៍ផ្សេងៗ លើកម្មវិធីអង្គការ(ស្តារ៉ូ)។ មណ្ឌលមានផលិត ចែកផ្សាយឯកសារ ពត៏មានការទំនាក់ទំនង និងការអប់រំ(IEC) ដើម្បីគាំទ្រដល់សកម្មភាពអប់រំ និង ការតស៊ូមតិទៅកម្មវិធីអង្គការ(ស្តារ៉ូ) ផ្សេងៗ។ នៅក្នុងឆ្នាំ ២០០៦ នេះមណ្ឌលបានផលិតឯកសារដូចជា៖

-សៀវភៅមេរៀនពិសេសសំរាប់ការងារផ្នែកខ្លះរបស់ស្តារ៉ូ រួមមាន សៀវភៅរៀបចំអភិវឌ្ឍន៍សហគមន៍ សៀវភៅអំពីការសំរបសំរួលកិច្ចប្រជុំសហគមន៍ សៀវភៅគ្រប់គ្រងនិងដឹកនាំសហគមន៍ សៀវភៅរៀបចំចងក្រងក្រុមជួយខ្លួនឯងនៃអ្នករើសសំរាម និងសៀវភៅជំនាញការទំនាក់ទំនង។

- ការរៀបចំកែសំរួលនិងដាក់ឯកសារថ្មីៗបន្ថែមក្នុងវ៉ិបសាយស្តារ៉ូ។

- របាយការណ៏ប្រចាំឆ្នាំ 2005 មានចំនួន 500 ក្បាល
- ខិត្តប័ណ្ណពត៏មាន(ស្តារ៉ូ) មានចំនួន 500 សន្លឹក
- អាវយឺតចំនួន 714 អាវ និង មួកចំនួន 100 មួក សំរាប់គាំទ្រដល់យុទ្ធនាការស្តារ៉ូ
- ប្រតិទិនចំនួន 500 សន្លឹក ផ្សព្វផ្សាយពីសកម្មភាពការងារស្តារ៉ូ
- រូបភាពគំនូរអប់រំ 60 រូប និងបដា 6 ផ្ទាំង សំរាប់គាំទ្រកម្មវិធីអប់រំស្តារ៉ូ
- ផ្ទាំងរូបភាព 1000 សន្លឹក ផ្សព្វផ្សាយអំពី ការបែងចែកសំរាម និងការអភិវឌ្ឍន៍សហគមន៍
- ខិត្តប័ណ្ណចំនួន 950 សន្លឹក ផ្សព្វផ្សាយអំពីការកែច្នៃសំរាម និងការធ្វើជីកំប៉ុស
- ឯកសារព័ត៌មាន 11 ច្បាប់ ផ្ទាំងរូបភាពធុងសំរាមចំនួន 10 ផ្ទាំង និង ផ្ទាំងរូបភាពធំៗចំនួន 2 ផ្ទាំង សំរាប់ធ្វើយុទ្ធនាការ។

# កម្មវិធីអភិវឌ្ឍន៍ស្ថាប័ន

**គោលបំណង(ស្តារ៉ូ)៖ ពង្រឹងសមត្ថភាពបុគ្គលិក ដើម្បីអោយមានប្រសិទ្ធភាពការងារកាន់តែប្រសើរថែមទៀត។**

### ការវាយតម្លៃអនុវត្តន៍ការងារនិងការអភិវឌ្ឍន៍បុគ្គលិក

ទ្រព្យធនដ៏មានតម្លៃបំផុតរបស់អង្គការ(ស្តារ៉ូ) គឺបុគ្គលិករបស់ខ្លួន និងកម្មវិធីអភិវឌ្ឍន៍ស្ថាប័ន ដែលធានាថា បុគ្គលិកទទួលបានការអភិវឌ្ឍន៍លើជំនាញរបស់ពួកគេជាបន្ត នៅពេលពួកគេធ្វើការងារជាមួយសហគមន៍។ បុគ្គលិកម្នាក់ៗទទួលការវាយតម្លៃលើការអនុវត្តន៏ការងាររបស់ខ្លួនប្រចាំឆ្នាំជាមួយមន្ត្រីរបស់ខ្លួន រួមនិងផ្នែកធនធានមនុស្ស ដើម្បីឆ្លុះបញ្ចាំងពីការងារជោគជ័យរបស់គេ និង តំរូវការបណ្តុះបណ្តាលបន្ថែមលើការងាររបស់គេ។ ផ្នែកធនធានមនុស្សបានតម្លើងឋានៈបុគ្គលិក 4 នាក់ ហើយជ្រើសរើសបានបុគ្គលិកថ្មី 2 នាក់ ក្នុងឆ្នាំនេះ។ ផ្នែកធនធានមនុស្សបានបង្កើតឯកសារ ស្តីពី ការពិពណ៌នាការងារ ទទួលខុសត្រូវ ហើយធ្វើការពន្យល់បកស្រាយទៅដល់បុគ្គលិកថ្មី។

### ការបណ្តុះបណ្តាល

បុគ្គលិក(ស្តារ៉ូ)បានចូលរួមការបណ្តុះបណ្តាលនៅក្នុងឆ្នាំ2006 នេះរួមមានវគ្គ ស្តីពី ធាតុបំពុលសរីរាង្គ មាចំនួន 3 ថ្ងៃ វគ្គស្តីពី ការវិភាគយេនឌ័រថ្នាក់ជាតិសំរាប់ការគ្រប់គ្រងបរិស្ថានទីក្រុង ចំនួន 3 ថ្ងៃ និងវគ្គបណ្តុះបណ្តាលគ្រូបង្គោលចំនួន 5 ថ្ងៃ។ មន្ត្រីធនធានមនុស្សបានរៀបចំ វគ្គសិក្សា 2 លើក ដល់បុគ្គលិកចំនួន 23 នាក់ (ស្ត្រី 8 នាក់) ស្តីពី គោលនយោបាយបុគ្គលិកអង្គការ(ស្តារ៉ូ) ទស្សនវិស័យបេសកកម្ម និង គោលបំណងរបស់អង្គការ(ស្តារ៉ូ)។

### ការអភិវឌ្ឍន៍រចនាសម្ព័ន្ធ

ផ្នែកធនធានមនុស្សបានរៀបចំសិក្ខាសាលាធ្វើផែនការយុទ្ធសាស្ត្រចំនួន 10 ថ្ងៃ នៅក្រុងព្រះសីហនុសំរាប់បុគ្គលិកសំខាន់ៗចំនួន 14 នាក់។ ហើយបង្កើតបានផែនការយុទ្ធសាស្ត្រថ្មី3ឆ្នាំ សំរាប់រយៈពេលពីឆ្នាំ2007ទៅឆ្នាំ2010។ ផែនការទើបតែបានបញ្ចប់ និងផ្សព្វផ្សាយនៅពេលឆាប់នេះ។

# Community Resource Center

**CSARO goal:** Improve communities' capacity to develop for a sustainable future.

The Community Resource Centre provides a small resource library to be used by the community and other development organisations and for CSARO programmes. It also produces and disseminates information, education and communication (IEC) materials to support education and advocacy activities in CSARO programmes. During 2006, the Centre produced: Special manuals for components of CSARO's work: a community development organising manual; a community meeting facilitation manual; a community management and leadership manual; a waste picker self-help group organisation manual; and a communication skills manual

- An update to the CSARO website, adding new documents with the assistance of a consultant
- 500 Annual Reviews for 2005
- 500 CSARO brochures
- 714 T-shirts and 100 caps to support CSARO campaigns
- 500 calendars promoting CSARO activities
- 60 educational pictures and six banners supporting CSARO education programmes
- 1,000 posters promoting waste separation and community development
- 950 leaflets promoting recycling and composting
- 11 informational materials, 10 Garbage bins and two billboards for campaigns



IEC materials. សំភារៈអប់រំផ្សព្វផ្សាយ

# Institutional Development Programme

**CSARO goal:** Strengthen CSARO staff capacity for greater effectiveness.

### Performance appraisal and staff development

CSARO's most important asset is its staff. The Institutional Development Programme ensures that staff continually develop their skills as they work with communities. Each member of staff has an annual performance appraisal, in which they work together with the human resources department (HRD) to reflect on their successes and their training needs. The HRD dealt with four promotions and the recruitment of two new staff during the year. New job descriptions were developed where necessary and an orientation programme was provided for new staff.

### Training

Training during 2006 included courses on Persistent Organic Pollutants (three days), national gender analysis training for urban environmental management (three days) and advanced training of trainers (five days). The HRD also conducted two workshops for a total of 23 staff (eight women) on the CSARO personnel policy and its vision, mission and goals.




សកម្មភាពបណ្តុះបណ្តាលសមត្ថភាពបុគ្គលិក
Staff Capacity Training Acitivity

### Organisational development

The HRD organised a 10-day strategic planning workshop for 14 key staff in Kompong Som. During this period, the new three-year strategic plan for 2007-2010 was developed. This has now been completed and published.